ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ០៥៣៧ ព.ណ.ច.ប.ត

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សេចក្តីជូនដំណឹង
## ស្តីពី
## ការតម្រូវឱ្យប្រើប្រាស់ឈ្មោះដែនជាតិ .com.kh និង ការផ្តល់អាសយដ្ឋានអេឡិចត្រូនិកឈ្មោះដែនជាតិនៅពេលប្រកាសប្រតិវេទន៍ប្រចាំឆ្នាំ

ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលជាប្រធានក្រុមហ៊ុនទាំងអស់ឱ្យបានជ្រាបថា អនុលោមតាមមាត្រា៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អំពីការធ្វើប្រតិវេទន៍ប្រចាំឆ្នាំ និងមាត្រា៧ នៃអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត បានកំណត់ឱ្យក្រុមហ៊ុនទាំងអស់ ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រើប្រាស់ឈ្មោះដែនជាតិកម្រិតទី២ ប្រភេទ .com.kh ហើយត្រូវផ្តល់អាសយដ្ឋានអេឡិចត្រូនិក ដែលមានឈ្មោះដែនជាតិកម្រិតទី២ ប្រភេទ .com.kh នេះ នៅពេលធ្វើប្រតិវេទន៍ប្រចាំឆ្នាំ ទាក់ទងនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម។

ក្នុងន័យនេះ សូមក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម ហើយពុំទាន់បានប្រើប្រាស់អាសយដ្ឋានអេឡិចត្រូនិក ដែលមានឈ្មោះដែនជាតិកម្រិតទី២ ប្រភេទ .com.kh នៅឡើយ ត្រូវប្រញាប់រួសរាន់មកចុះឈ្មោះស្នើសុំប្រើប្រាស់ឈ្មោះដែនជាតិកម្រិតទី២ ប្រភេទ .com.kh នៅនិយ័តករទូរគមនាគមន៍កម្ពុជា ដែលមានអាសយដ្ឋាន វិថីលេខ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬតាមរយៈអ៊ីមែល info@trc.gov.kh ឬទូរសព្ទលេខ **៦៧៨៩** នៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការ។ ទន្ទឹមនឹងនេះ ចំពោះក្រុមហ៊ុនដែលត្រូវប្រកាសប្រតិវេទន៍ប្រចាំឆ្នាំទាក់ទងនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ តទៅ ត្រូវផ្តល់អាសយដ្ឋានអេឡិចត្រូនិក ដែលមានឈ្មោះដែនជាតិកម្រិតទី២ ប្រភេទ .com.kh នៅពេលប្រកាសប្រតិវេទន៍ប្រចាំឆ្នាំ។ សម្រាប់ព័ត៌មានពាក់ព័ន្ធនឹងក្រសួងពាណិជ្ជកម្ម សូមទាក់ទងទូរសព្ទលេខ ០៩២ ៥៦៩ ៧៧៦ ឬ ០៩២ ៨៨៦ ៦៨៨ ឬតាមរយៈអ៊ីមែល ecommercelicensing@moc.gov.kh ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលជាអភិបាលក្រុមហ៊ុនទាំងអស់មេត្តាជ្រាប និងអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត តាមការចាំបាច់។

ថ្ងៃ សុក្រ ១៥កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែមេសា ឆ្នាំ២០២២

ក្រសួងពាណិជ្ជកម្ម

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរសព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469